# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0150**

## សម្ភាសន៍ជាមួយឈ្មោះ មុំ គីង ភេទស្រី អាយុ៥៧ឆ្នាំ
## មុខងារជំនាន់ខ្មែរក្រហម "ប្រជាជនធ្វើការនៅកងចល័ត"
## រស់នៅភូមិកណ្តាល ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ឆាយ ឈុនលី
## ០០:៥០:២៨
## ២៤ទំព័រ

ឈុនលី ៖ អ៊ីចឹងជាដំបូងខ្ញុំសុំណែនាំខ្លួនសិនមីង ។ ខ្ញុំឈ្មោះឈុនលីមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំមកជួបមីងដូចខ្ញុំបានជំរាបមីងអ៊ីចឹង ដើម្បីសួរនាំរឿងប្រវត្តសាស្រ្តកាលសម័យខ្មែរ ក្រហមពីការលំបាករបស់មីងយ៉ាងម៉េចខ្លះអ៊ីចឹង ដើម្បីយកទៅចងក្រងជាសៀវភៅហើយ ដើម្បីទុកឲ្យក្មេងជំនាន់ក្រោយបានរៀនបានសូត្រអ៊ីចឹងណាសមីង ។

គីង ៖ ចាស!

ឈុនលី ៖ ហើយនៅក្នុងនោះខ្ញុំសុំថតរូបមីងដែរហើយក្នុងនោះមានថតសំលេងខ្ញុំកត់អត់ទាន់អ៊ីចឹងពេលទៅដល់កន្លែងវិញខ្ញុំយកមកវៃជាអត្ថបទ ។ អ៊ីចឹងអត់អីទេមីងហ្ន៎?

គីង ៖ ចាស!

ឈុនលី ៖ អ៊ីចឹងថ្ងៃនេះទី១៦ ហើយខ្ញុំសុំស្គាល់ឈ្មោះមីងម្តងទៀត មីងឈ្មោះអី?

គីង ៖ ឈ្មោះ មុំ គីង ។

ឈុនលី ៖ មុំ គីង អាយុប៉ុន្មានហើយមីង?

គីង ៖ ខ្ញុំ៥៧ ។

ឈុនលី ៖ រស់នៅភូមិ?

គីង ៖ កណ្តាល!

ឈុនលី ៖ ភូមិកណ្តាល ឃុំព្រះនេត្រព្រះ ។

គីង ៖ ស្រុកព្រះនេត្រព្រះ!

ឈុនលី ៖ ចា៎!ខេត្តបន្ទាយមានជ័យ ។ មីងមានបងប្អូនប៉ុន្មាននាក់?

គីង ៖ ខ្ញុំ បងប្អូនខ្ញុំប្រាំមួយនាក់ ។

ឈុនលី ៖ ប្រាំមួយនាក់ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

គីង ៖ ស្រីពីរ ប្រុសពីរ ។

ឈុនលី ៖ មីងកូនទីប៉ុន្មាន?

គីង ៖ ខ្ញុំ កូនទី១ ។

ឈុនលី ៖ បងគេ?

គីង ៖ ចា៎!

ឈុនលី ៖ ឪពុកឈ្មោះអី?

គីង ៖ គាត់ស្លាប់ហើយ ឈ្មោះ មុំ ឆម ។

ឈុនលី ៖ ឆម ម្ដាយ?

គីង ៖ ម្ដាយឈ្មោះ ប៉ែន កែប ។

ឈុនលី ៖ មីងធ្លាប់រៀនបានថ្នាក់ទីប៉ុន្មាន?

គីង ៖ ខ្ញុំរៀនថ្នាក់ទីប្រាំបួនចាស់ ។

ឈុនលី ៖ ហ៊ឺស!គ្រាន់បើហើយមីង!ថ្នាក់ទីប្រាំបួនដូចស្មើថ្នាក់ទី៤ ទី៥ហ្អី?

គីង ៖ ចាស!

ឈុនលី ៖ ចុះមីង កាលមុនខ្មែរក្រហមមីងធ្វើអីគេ? នៅភូមិណាវិញ?

គីង ៖ ខ្ញុំនៅទីនេះឯង!

ឈុនលី ៖ ស្រុកកំណើតនៅហ្នឹងដែរ?

គីង ៖ ចាស!

ឈុនលី ៖ ទឹកដីហ្នឹងម៉ង?

គីង ៖ ចាស! មុនខ្មែរក្រហមខ្ញុំទៅនៅរៀនដេរនៅបាត់ដំបងឯណោះ ។

ឈុនលី ៖ អាហ្នឹងឆ្នាំណាដែរ?

គីង ៖ ហុក ៧៥ នៅឯណោះឯង ។

ឈុនលី ៖ នៅឯណោះ?

គីង ៖ ចាស!

ឈុនលី ៖ ចុះអាខ្ទង់៧៣ ៧៤នៅឯណា?

គីង ៖ នៅឯណោះ ខ្ញុំនៅតាំងពីតូចអាយុ១២ឆ្នាំ ។

ឈុនលី ៖ ទៅហ្នឹងទៅតាំងពី១២ឆ្នាំ ម៉េចបានទៅចឹង?

គីង : ទៅ ដូចថាមានបងប្អូនគេយកឲ្យទៅនៅជាមួយគេនោះណាស ដល់នេះទៅគេឲ្យទៅរៀនដេរ
រៀនអីនោះណាស ។

ឈុនលី : ចឹងស្នាក់នៅជាមួយបងប្អូន?

គីង : ចាំ!

ឈុនលី : ត្រូវជាយ៉ាងម៉េច?

គីង : បងប្អូនរាងឆ្ងាយហើយ ត្រូវជាជីដូន ។

ឈុនលី : ប្រហែលឆ្នាំណាទៅមីងហ្នំ?

គីង : ប្រហែលហុកប៉ុន្មានទេ...

ឈុនលី : តាំងពីឆ្នាំហុកជាង?

គីង : ចាស!ព្រោះ៧៥នេះគេជម្លៀសចេញពីបាត់ដំបង ។

ឈុនលី : នៅបាត់ដំបងនៅស្រុកអីគេ?

គីង : ដូចមិនមែនស្រុកសង្កែ នៅខាងនេះស្ទឹងណាសនាង ត្រើយខាងនេះណាស មិនមែនស្រុក
សង្កែទេ ។

ឈុនលី : មិនដឹងស្រុកអីគេទេមីង! ១២ឆ្នាំនៅបាត់ដំបងជាមួយបងប្អូន ។ នៅហ្នឹងរបៀបទៅរៀន
ដេរ ហើយជួយការងារគេហ្អី?

គីង : ចាស!ជួយការងារគេបានគេឲ្យយើង...

ឈុនលី : ហើយរៀនដេរនៅទីនោះ?

គីង : ចាស!តែរៀនដេរមិនទាន់បានចេះផងបាន ប៉ុល ពត ទៅតែបានដេរខ្វះៗ ។

ឈុនលី : ចុះ អាពត ចូលនៅនោះតាំងពីឆ្នាំណា?

គីង : ឆ្នាំ៧៥ ហើយខ្ញុំគេជម្លៀសចេញមកតែម្តង ជម្លៀសចេញពីបាត់ដំបង ។

ឈុនលី : ចូលនៅបាត់ដំបងហ្នឹង?

គីង : ចាស!

ឈុនលី : ហើយទៅជម្លៀសមកវិញ?

គីង : ចាស!

ឈុនលី : ជម្លៀសមកណា?

គីង : ជម្លៀសមកស្រុកកំណើតខ្លួនឯងហ្នឹង ។

ឈុនលី : ជម្លៀសចេញមកនេះវិញ?

គីង : ចាស!

ឈុនលី : ជាមួយអ្នកណាខ្លះទៅ?

គីង : ជាមួយឪពុកមារម្ដាយមីងដែលនៅជុំគាត់នេះឯង ។

ឈុនលី : ហើយជាមួយអ្នកផ្សេងទៀតដែរ?

គីង : តែម៉ាគ្រួសារហ្នឹងឯង ។

ឈុនលី : ចុះអ្នកផ្សេងទៀតអ្នកនៅបាត់ដំបងដូចគ្នា?

គីង : ជម្លៀសមកទាំងអស់គ្នាតែមិនដឹងគេទៅណាទេ ដូចយើងមានគោលដៅនៅនេះយើងមកនេះ ។

ឈុនលី : ចុះគេប្រាប់ថាម៉េចពេលជម្លៀសហ្នឹង?

គីង : ចាំមើលណាស ដូចកាលនោះគេមិនទាន់ប្រាប់ទេដូចខ្ញុំនៅក្នុងក្រុងគាត់អត់ឲ្យយើងចេញចឹងណាស់ គេប្រាប់ថាអ្នកក្រុងអត់ទាន់ឲ្យចេញហើយខ្ញុំអត់ទាន់បានរៀបអីទេដល់ក្រោយមកជម្លៀសអ្នកដែលភៀសខ្លួនមក ចេញមកបានគេប្រកាសប្រាប់ថាអ្នកក្នុងក្រុងក៏គេឲ្យចេញមកដែរបានពួកខ្ញុំចេញមក ។

ឈុនលី : ចុះគេមានប្រាប់ថាឥឡូវស្រុកកំណើតនៅឯណាឲ្យទៅវិញអីអត់ទេ?

គីង : ទេ គេមិនបានប្រាប់ទេ យើងមកខ្លួនយើងស្រុកកំណើតនៅឯណាយើងទៅៗ ។

ឈុនលី : យើយអីចឹងយើងមិនដើរបែកគ្នា?

គីង : ដើរបែកគ្នា!

ឈុនលី : គេអត់ថាអីគេហ្អីចឹង?

គីង : អត់ថាអីទេ ។

ឈុនលី : យើងមកដល់ស្ថានភាពយ៉ាងម៉េចទៅមីង?

គីង : មកដល់ មីងខ្ញុំគាត់ទៅខាងភ្នំស្រុក ដែលខ្ញុំមកជាមួយហ្នឹងគាត់ទៅខាងភ្នំស្រុកហើយមកដល់ខ្ញុំក៏នៅជាមួយម្ដាយខ្ញុំទៅ ។

ឈុនលី : ហើយមកដល់ឃើញស្រុកភូមិយ៉ាងម៉េចដែរ?

គីង : មកដល់ឃើញស្រុកភូមិនេះគេជម្លៀសទៅនេះហើយហ្នឹង ទៅភូមិស្រែះ ទៅស្រុកស្រែះយើងនេះ ។

ឈុនលី : ភូមិឬស្រុក?

គីង : ភូមិ ភូមិស្រេហ ភូមិស្រែះខាងកើត ។

ឈុនលី ៖ ចុះម្ដាយមីងទៅដែរ?

គីង ៖ ចាស!

ឈុនលី ៖ ចឹងមកដល់អត់ឃើញអីទេចឹង?

គីង ៖ អត់ទេ អត់មានឃើញអីទេព្រោះគេជម្លៀសទៅអស់ហើយ ។ ខ្ញុំមិនចាំខែថ្ងៃទេ ។

ឈុនលី ៖ អត់អីទេមីងឲ្យតែចាំឆ្នាំ ។ ដល់ពេលចេញអស់ទៅមីងធ្វើម៉េចទៅ?

គីង ៖ ខ្ញុំទៅតាមគាត់នៅឯស្រុះណុងឯង ។

ឈុនលី ៖ គេប្រាប់ហ្អីបានដឹង?

គីង ៖ ចា៎!គេប្រាប់ឪពុកម្ដាយគេជម្លៀសទៅនោះអស់ហើយ ។

ឈុនលី ៖ ហើយទៅនោះយ៉ាងម៉េចខ្លះទៅ?

គីង ៖ ទៅចឹងគេឲ្យធ្វើការទៅបោចស្មៅបោចអីហ្នឹងណាស នៅវាលនាមអីណាស!

ឈុនលី ៖ បោចអីគេមីង?

គីង ៖ បោចវល្លិស្មៅតាមស្រែណាសឲ្យគេភ្ជួរ ។

ឈុនលី ៖ វល្លិស្មៅ?

គីង ៖ ចាស!

ឈុនលី ៖ ហើយហូបចុកអីយ៉ាងម៉េចទៅ?

គីង ៖ កាលនោះហូបចុកមិនទាន់អីទេព្រោះអង្ករយើងមិនទាន់អស់ ។

ឈុនលី ៖ ហូបបាយរៀងខ្លួន?

គីង ៖ ចាស ហូបបាយរៀងខ្លួន ។

ឈុនលី ៖ ចុះនៅរបៀបម៉េច?

គីង ៖ រស់នៅតាមខ្ទមណាស ធ្វើខ្ទម ។

ឈុនលី ៖ នៅខ្ទមហ្នឹងរបៀបជុំគ្នា?

គីង ៖ ធ្វើខ្ទមនៅម៉ាភូមិៗណាស!

ឈុនលី ៖ មិនមែននៅរបៀបគ្រួសារជាមួយឪពុកម្ដាយទេ?

គីង ៖ ចា៎!នៅជាមួយឪពុកម្ដាយ ប៉ុន្តែសរុបម៉ាភូមិដូចនៅភូមិប៉ុស្តិចាស់ចឹងដាក់តាមភូមិប៉ុស្តិចាស់ ភូមិកណ្ដាលដាក់តាមភូមិកណ្ដាលចឹងទៅ តាមគ្រួសារដូចយើងនៅចឹង តែហូបធម្មតាកាលនោះណាសវាមិនទាន់យ៉ាប់ទេ ។

ឈុនលី ៖ មិនទាន់មានសហករណ៍មានអី?

គីង : អត់ទេ ។

ឈុនលី : ហើយដូចម្តាយមីងគាត់ចាស់ចឹងគាត់ធ្វើអី?

គីង : ទេ គាត់មិនបានទៅទេ គេមិនបានឲ្យធ្វើអីទេ ។ អាកាលភ្លាមៗនោះវារបៀបថាដូចស្រួល ណាស ដល់ក្រោយមកបានយ៉ាប់ ។

ឈុនលី : ចាប់ពីឆ្នាំណាមកបានយ៉ាប់?

គីង : ៧៦ ៧៦ដឹងតែយ៉ាប់ហើយ ។

ឈុនលី : យ៉ាប់ម៉េចខ្លះទៅមីង?

គីង : យ៉ាប់ត្រង់ថាគេឲ្យយើងទៅលើកទំនប់លើកអីណាស ។

ឈុនលី : លើកទំនប់ណាទៅដំបូង?

គីង : ពួកខ្ញុំគេឲ្យទៅលើកទំនប់នៅគោករំចេកឯស្រុកភ្នំស្រុកណោះណាស ។

ឈុនលី : ចុះពេលណាបានគេរៀបសហករណ៍នៅស្រែះនេះ?

គីង : អត់ទេ ចាំមើលណាស ពួកខ្ញុំបានទៅនៅស្រែះប្រហែលជាម៉ាខែ ។ មិនដឹងជាម៉ាខែឬពីរខែ ទេបានគេជំលៀសទៅនៅភូមិប៉ោយព្រីង ភូមិយើងជាប់ខាងជើងភ្នំនេះ ដល់ជម្លៀសមក បានគេឲ្យយើងទៅលើកទំនប់គោករំចេកជិតព្រៃមាន់ ។

ឈុនលី : គេមានប្រាប់ទេថាទៅលើកទំនប់ធ្វើអី?

គីង : ទេ គេអត់មានប្រាប់យើងទេគ្រាន់តែគេឲ្យទៅលើក ។ ខ្ញុំទៅពីរនាក់ប្អូនប្រុសម្នាក់ទៅលើក ទំនប់ ។

ឈុនលី : ហើយមនុស្សច្រើនទេ?

គីង : ច្រើនមនុស្សច្រើន ហើយសុទ្ធតែដើរអត់មានស្អីជិះទេ យើងដើរហើយយើងស្ពាយឥវ៉ាន់ ណាស ។ អត់មានអីជិះទេ ហើយវាប្រាប់ឲ្យយើងម៉ោងប្រាំចេញពីស្រុកនេះទៅ ដើរទាំង យប់ កាលពួកខ្ញុំដើរទាំងយប់ ។

ឈុនលី : ចុះបងប្អូនមីងផ្សេងទៀតធ្វើអី?

គីង : បងប្អូនខ្ញុំប៉ុន្មាននាក់ទៀតនៅតូចៗ ធំតែខ្ញុំប៉ុន្មាននាក់ទេ ។

ឈុនលី : ហើយគេឲ្យហូបបបរឬហូបបាយកាលទៅលើកទំនប់?

គីង : លើកទំនប់គេឲ្យយើងហូបបាយ តែដូចតែយើងចែកគ្នា ។ ដូចថាបីវែកៗទាំងអស់គ្នា ពីរវែកៗទាំងអស់គ្នា ។ ប៉ុន្តែសម្លនោះ...សម្លដូចយើងស្លម្ជូត្រកួនតែទាំងខ្ទះៗហូប ។ ដល់ នេះទៅខ្ញុំឈឺ ឈឺហើយមកវិញដេកពេទ្យស្រុកនេះឯង ។

ឈុនលី : ធ្វើការហ្នឹងគេចែកយ៉ាងម៉េចខ្លះទៅ? ទំហមដី?

គីង : ម៉ាងៃគេឲ្យយើងពីរម៉ែត្រគីប ។

ឈុនលី : ដំរៅប៉ុន្មាន?

គីង : ដំរៅកន្លះ លើពីរម៉ែត្រ ។

ឈុនលី : ដំរៅតែកន្លះម៉ែត្រទេ?

គីង : ចាស តែបណ្តោយបេះពីរម៉ែត្រ ។

ឈុនលី : ទទឹងពីរម៉ែត្រដែរ?

គីង : ទទឹងម៉ាម៉ែត បណ្តោយពីរម៉ែត្រក្នុម៉ាងៃឲ្យយើងរែកឲ្យរួច ប៉ុន្តែខ្ញុំកំលាំងខ្សោយទាល់តែល្ងាចៗបានរួច ហើយខ្ញុំមិនមែនមាឌធំបេះអីតូច ស្គមណាស ពីដើមខ្ញុំស្គម ។

ឈុនលី : ហើយចុះអ្នកណាដែររួចមុនចឹងទំនេរ?

គីង : ចាស ទំនេរគេទៅសំរាកមុន យើងនៅក្រោយក៏នៅក្រោយទៅណាស ។

ឈុនលី : ចុះមានអ្នកណាគេដែលធ្វើអត់ហើយដល់យប់ដល់អីទេ?

គីង : ទេ ដូចមិនដែលមានទេ ដូចម៉ាងៃពីរម៉ែត្រគីបចឹងបេះតែនាំគ្នាខំទៅណាស ។ ដល់ពេលបាយគេឲ្យយើងទៅបាយ បាយហើយយើងទៅទៀតដល់ម៉ោងបួនចឹងទៅណាសម៉ោងពីរម៉ោងបី ម៉ោងប្រាំស្រេចតែកំលាំងគេតូចធំចឹងទៅណាស ។ ដូចខ្ញុំកំលាំងតូចខ្លះណាដល់ល្ងាចទៅ ប៉ុន្តែខ្ញុំអាឆ្នាំ៧៦ ដូចចូល៧៧ហើយខ្ញុំបើកវគ្គ ខ្ញុំបើកនៅទំនប់កំបោរស្រែះនេះដល់បើកវគ្គទៅគេឲ្យទៅលើកទំនប់រហូត ។

ឈុនលី : ហើយទៅលើកទំនប់ហ្នឹងមានទឹកស្អាតសហូបទេ?

គីង : អត់មានទេ ។

ឈុនលី : ចុះទឹកមុជទឹកអីនោះ?

គីង : យើងមុជទឹកប្រឡាយហើយមុជទឹកត្រពាំងដីកទឹកត្រពាំងនោះឯងអត់មានទឹកអីស្អាតទេ ។

ឈុនលី : ប៉ុន្តែគ្រាន់តែថាម៉ាគ្រប់ ហើយយើងមានទឹកមុជទឹកអី?

គីង : ចាស មាន ។

ឈុនលី : អ្នកណាគេអ្នកដឹកនាំឲ្យជីកប្រឡាយនៅនោះ?

គីង : អាកាលខ្ញុំនៅទំបន់កំបោរស្រែះនេះឈ្មោះអីទេ ឈ្មោះរ៉ាល់...

ឈុនលី : ឈ្មោះរ៉ាល់?

គីង : ចា៎ ដូចជាប្រធានតំបន់ ។

ឈុនលី ៖ គេហៅគណៈតំបន់ទេដឹង?

គឹង ៖ ចាំ គណៈតំបន់ឈ្មោះ វ៉ាល់ ។

ឈុនលី ៖ ប្រុសហ្អី?

គឹង ៖ ប្រុស ។

ឈុនលី ៖ គាត់អ្នកអីណាទៅ?

គឹង ៖ នៅតំបន់ យើងអត់ដឹងថាស្រុកណាទេយើងមិនហ៊ានមើលមុខគេទៀត ។

ឈុនលី ៖ ចុះអត់ដែលស្គាល់គាត់ពីដើមមកទេ?

គឹង ៖ អត់ដែលស្គាល់ទេ ទើបតែទៅទំនប់នេះបានស្គាល់ ។

ឈុនលី ៖ គាត់កាចដែរ?

គឹង ៖ ហ្អូស!គាត់កាចគ្រាន់បើដែរ ។

ឈុនលី ៖ តាវ៉ាល់!

គឹង ៖ ចាំ! គេហៅតែ តាវ៉ាល់ៗ ។

ឈុនលី ៖ ចុះពេលមីងធ្វើការនៅនោះមានដែលឃើញគេយកមនុស្សទៅណាទេ?

គឹង ៖ ខ្ញុំមិនដែលពិបាកទេ!

ឈុនលី ៖ តែដូចយើងបានឃើញបានឮអីចឹងទៅ?

គឹង ៖ បើឮនិយាយឮ តែឲ្យឃើញអត់ឃើញទេ ។

ឈុនលី ៖ ឮគេនិយាយថាម៉េចទៅ?

គឹង ៖ ទេ ដូចគេនិយាយថាគេចាប់អ្នកនេះចាប់អ្នកនោះទៅយើងចេះតែខ្លាច ។

ឈុនលី ៖ ហើយចុះអ្នកដែលគេចាប់ទៅហ្នឹងមីងស្គាល់ទេ?

គឹង ៖ អត់ទេ ។

ឈុនលី ៖ ហើយពេលទៅធ្វើការហ្នឹងមានប្រជាជនថ្មីប្រជាចាស់ទៅទាំងអស់គ្នាទេ?

គឹង ៖ មាន នៅជុំគ្នាខ្ញុំនៅជាមួយគ្រួសារខ្ញុំហ្នឹងមានប្រជាជនថ្មីប្រជាជនចាស់ជាមួយគ្នា ប៉ុន្តែខ្ញុំប្រជាជនចាស់ហ្នឹងគេធ្វើបាបដែរហ្នឹង ។

ឈុនលី ៖ ម៉េចទៅមីង?

គឹង ៖ ដូចយើងគ្រុនចឹងណាស គ្រុនយប់តែភ្លឺឡើងយើងអត់គ្រុនទេ យើងស្វាង យើងត្រូវទៅធ្វើការ ។ ដល់ខ្ញុំនេះទៅធ្វើការធ្វើអត់រួចទេ ប្ដីខ្ញុំឆ្លងស៊ឹងនៅទំនប់ស្ទាច់ ស្ទាច់តាខែកយើងនេះនៅជិតភ្នំស្រុក ដូចថាយើងដឹកអត់រួចអីចេះ វាមិនទាន់ធ្វើបាបយើងទេ ប៉ុន្តែខ្លាចវាអត់រួច

ប្ដីយើង តែប្ដីយើងធ្វើការងារផ្សេងណាស ប្រពន្ធធ្វើផ្សេង ។ ដល់ខ្ញុំឈឺចេះទៅ ប្ដីខ្ញុំគាត់ដឹងថាខ្ញុំរែកអត់រួចគាត់ឆ្លងស្ទឹងទៅជួយរែក ។

ឈុនលី : មីងការយូរហើយហ្អស?

គីង : ខ្ញុំតាំងពី៧៧ ។

ឈុនលី : ការ៧៧ ចុះអាពេលទៅរែកទំនប់នេះចិតប៉ុន្មាន?

គីង : ខ្ញុំចាំមើលណាសទៅតាំងពីចុង៧៥ ទៅ៧៥ទៅតាំងពីនៅលីវទៅគោករមចេក ដល់បើកវគ្គទៅ...កាលមុនខ្ញុំដេរណាស ដែលទៅបើកវគ្គជាមួយគាត់ហ្នឹងខ្ញុំទៅដេរខោអាវណាស ។ ដល់បើកវគ្គទៅខ្ញុំទៅនៅជាមួយប្ដីខ្ញុំ ប្ដីខ្ញុំទៅលើកទំនប់ គេឲ្យទៅនៅនោះ ។

ឈុនលី : ចុះអាកាលលើកទំនប់គោករំចេកហ្នឹងទៅលើកខ្លួនឯង?

គីង : ចាស កាលនោះនៅលីវណាស ឡូ

ឈុនលី : ហើយការហ្នឹងគាត់ស្នើរសុំឬយ៉ាងម៉េច?

គីង : ទេ នេះដូចថាភូមិជិតគ្នារួចទៅគេស្នើ គេស្នើទៅអង្គការ តែគេទៅដល់ម៉ែឪយើងដែរណាស ។

ឈុនលី : ចឹងបានន័យថាស្គាល់គ្នា?

គីង : ចា៎!គាត់នៅភូមិជើងវត្តនេះដែរ ។

ឈុនលី : ចុះពេលទៅត្រពាំងថ្មហ្នឹងពេលណា?

គីង : ខ្ញុំអត់បានទៅទេ ទំនប់ត្រពាំងថ្មអត់បានប៉ះសោះ ដល់ពេលទំនប់ត្រពាំងថ្មខ្ញុំពោះធំ អត់បានប៉ះទេ ។

ឈុនលី : ចុះដែលមីងធ្វើការខ្លាំងហ្នឹងនៅទំនប់អីគេ...ដែលបើកវគ្គ?

គីង : កំបោរស្រែះ ។

ឈុនលី : កំបោរស្រែះ ធំទេអាហ្នឹង?

គីង : ធំ ធំទៅដល់កំបោរ ពីស្រែះកើត ។

ឈុនលី : អាហ្នឹងឆ្ងាយពីត្រពាំងថ្មទេ?

គីង : ឆ្ងាយ ត្រពាំងថ្មនៅខាងស្រុកភ្នំស្រុក អានេះនៅស្រុកព្រះនេត្រព្រះ ។

ឈុនលី : ហើយទំនប់កំបោរស្រែះហ្នឹងធ្វើរយៈពេលប៉ុន្មានទៅ?

គីង : អត់ចាំទេ ព្រោះវាលើកមុនពេលខ្ញុំបើកវគ្គ ខ្ញុំឡើងបើកវគ្គបានៗទៅលើក ខ្ញុំទៅលើកបានប្រហែលពីរខែក៏រួច ។ រួចទៅគេលេងសីល្បះលេងអីបិទវគ្គចឹងទៅបានទៅលើកទំនប់ចេញ

ទៅស្រះទៀត ដល់លើកអានេះរួចទៅលើកនៅស្ទាប់ ស្ទាប់តាខែក ទៅគ្រាន់តែទៅជុំគ្នា ប្ដីប្រពន្ធគេឲ្យនៅផ្សេងគ្នា ដល់ខ្ញុំឈឺទៅគាត់មកជួយលើកខ្ញុំបានបីបួនប្រាំថ្ងៃ ដល់ខ្ញុំឈឺគ្រុន អត់បាត់ទៅគេឲ្យខ្ញុំទៅដេកពេទ្យ ។ ដល់ទៅដេកពេទ្យទៅខ្ញុំយំ ទឹកអីបេះឯងដេក និយាយពីវេទនា សម័យនោះវេទនាណាស់ខ្ញុំយំគេថាយើងឈឺអីទេ...ហើយថ្នាំមិនដែលបានលេបទេ ដល់គ្រួសារខ្ញុំទៅមើលបានគេឲ្យ ។ គេសួរយើងថាធ្វើការពីត្រឹមណាៗមក ខ្ញុំថាធ្វើយូរ ហើយតែគេអត់ជឿយើងណាស ចឹងទៅគេអត់សួរមើលយើងទេទាលតែប្ដីខ្ញុំទៅបានគេឲ្យ ថ្នាំមកបានលេប ។ បានលេបទៅដូចថាយើងស្វាង ជាណាស ។ ជាទៅគេយកខ្ញុំទៅដេរនៅជប់ ស្រុកព្រះនេត្រព្រះ ។

ឈុនលី ៖ ដេរ?

គីង ៖ ចា៎! ដេរខោអាវឲ្យពួកយុវជននារីខ្ញុំនៅដេរដល់ពេលពោះធំទៅខ្ញុំសុំគេមកនៅភូមិក្រោយមក អត់បានទៅណាទៀតទេនៅភូមិរហូត ។

ឈុនលី ៖ នៅរហូតម៉ង?

គីង ៖ ចា៎! នៅរហូត ។

ឈុនលី ៖ ចុះដល់ពេលគ្រួសារមីងអត់បានទៅធ្វើការនៅត្រពាំងថ្មដែរ?

គីង ៖ អត់ទេ គ្រួសារខ្ញុំក៏អត់បានទៅ ។

ឈុនលី ៖ ចុះមានបងប្អូនណាបស់មីងបានទៅទេ?

គីង ៖ បងប្អូនខ្ញុំអត់មានទេ ព្រោះបងប្អូនខ្ញុំនៅតូចៗ ។

ឈុនលី ៖ ចុះអាពេលមីងដេរនៅភូមិហ្នឹងក្នុងឆ្នាំណាហើយ?

គីង ៖ ខ្ញុំដេរដូចជា៦៧...

ឈុនលី ៖ ៧៧?

គីង ៖ ហ្នស!៧៧ ។ ៧៧ ៧៨ខ្ញុំមកនៅភូមិម៉ងដល់៧៩សន្តិភាពនេះឯង ខ្ញុំអត់មានបានទៅណាទៀតទេ ។

ឈុនលី ៖ ចុះមីងនៅក្នុងភូមិនេះមានដឹងសភាពការណ៍យ៉ាងម៉េចដែរ?

គីង ៖ ទេ នៅភូមិខ្ញុំអត់អីទេធម្មតា តែឮតែគេថាយកអ្នកនេះទៅវៃយកអ្នកនោះទៅវៃ តែយើងមិនបានឃើញទេបានតែឮ យើងទៅតែធ្វើការ ។ ដូចថាយើងជំនុំគ្នាក៏មិនបានដែរណាស នាង ទាល់តែគេឲ្យយើងទៅធ្វើការ ដាំដំឡូងដាំអី ទៅស្ទូងស្រូវស្ទូងអីតែខ្ញុំមកនៅភូមិនេះគេឲ្យខ្ញុំប៉ះខោអាវឲ្យអ្នកស្រុក ។

ឈុនលី : ខោអាវខ្មៅ?

គឹង : ចាំ! ខោអាវខ្មៅដែលអ្នកស្រុកស្លៀកពាក់ អត់មានខ្មៅ ពណ៌អីក៏ដោយ ។

ឈុនលី : អត់មានកាត់ថ្មីទេ?

គឹង : អត់ទេ ដូចថាអ្នកណារហែកប្ុរហូតផ្ទេររបូតអីហើយរហែកត្រង់ណាយើងចេះតែប៉ះឲ្យទៅ ។

ឈុនលី : សំបូរគេអ្នកយកមកដែរ?

គឹង : ចាស!

ឈុនលី : កាលនោះភូមិស្រែះហ្នឹងហ្អីដែលមីងថាមកនៅភូមិ?

គឹង : ខ្ញុំនៅភូមិកណ្តាលនេះឯង តែគេអត់ឲ្យយើងនៅភូមិនេះទេនៅឯដើងភ្នំទាល់តែសន្តិភាពបាន
គេឲ្យមកនៅភូមិនេះវិញ ។

ឈុនលី : អីចឹងខ្ទម ផ្ទះអីធ្វើថ្មី?

គឹង : ធ្វើថ្មី ខ្ទម តែគេអត់ឲ្យយើងនៅនេះទេនៅឯដើងភ្នំជម្មៀសទាល់តែសន្តិភាពបានគេឲ្យមក
នៅភូមិយើងវិញ ។

ឈុនលី : ចឹងនៅជាមួយអ្នកណាគេ?

គឹង : នៅជាមួយពុកម៉ែខ្ញុំនេះឯង ។

ឈុនលី : ចុះម៉េចបាននៅជុំគ្នា?

គឹង : ទេ អត់បានបែកគ្នាទេ បើគាត់ទៅនៅនោះហើយខ្ញុំទៅនៅជាមួយគាត់ ។

ឈុនលី : ចុះពេលនោះមីងថាពោះធំបានមកនៅក្នុងភូមិ?

គឹង : ចាស!

ឈុនលី : ចុះអ្នកផ្សេងទៀតម៉េចបានមកនៅភូមិដែរ?

គឹង : ទេ ខ្លះដូចថាគេហ៊ានស្នើបានមកនៅហើយ បើពួកដែលចាស់ៗគេឲ្យនៅភូមិដាំដំឡូងដាំអី ។

ឈុនលី : ចុះភាគច្រើនប្រជាជនចាស់ទៅនៅស្រែះចឹងអ្នកណាគេមកនៅក្នុងភូមិ?

គឹង : ពួកប្រជាជនថ្មី ។

ឈុនលី : មកពីខាងណាវិញ?

គឹង : មកពីភ្នំពេញ!

ឈុនលី : ហើយខាងណាទៀត?

គឹង : ពួកអរិយក្សត្រអីហើយដែលនៅតាមភូមិនេះហើយខ្ញុំនៅឯព្រៃឯណោះ ។

ឈុនលី : ចុះតាកែវអីមានដែរ?

គីង : ទេតាកែវដូចមានដែរ ទេតាកែវដូចមិនមានទេ មានតែអរិយក្សត្រ អរិយក្សត្រនិងភ្នំពេញ ដូចជាកំពង់ស្ពឺ តែអាភូមិផ្សេងៗខ្ញុំមិនដឹងទេ ។

ឈុនលី : ហើយពួកគាត់ប្រជាជនថ្មីចឹងឲ្យធ្វើការអីគេ?

គីង : ធ្វើការដូចតែគ្នា ។

ឈុនលី : ក្នុងភូមិហ្នឹង?

គីង : ចា៎!ដូចជាដាំដំឡូង ស្ទូងស្រូវ ខ្លះត្បាញកន្សែង ខ្លះត្បាញសំពត់កប្បាសយើងអាសនោះ គេឲ្យយើងត្បាញ ។

ឈុនលី : ហើយហូបចុកយ៉ាងម៉េចទៅអ្នកនៅក្នុងភូមិ?

គីង : អូ!អ្នកនៅក្នុងភូមិហូបយ៉ាប់ណាស់ ម៉េចបានថាយ៉ាប់ដូចថាម៉ាខ្ទះហ្នឹងរាវ ម៉ាខ្ទះធំគេឲ្យតែ ២០កំប៉ុងបបរហើយហូបម៉ាភូមិ ។

ឈុនលី : ២០កំប៉ុង?

គីង : ចាស!

ឈុនលី : ហើយហូបប៉ុន្មានពេល?

គីង : តែម៉ាពេល តែបបរនោះរាវរាវមិនមែនអាបបរខាប់ទេណាស រាវរាវ ។

ឈុនលី : បើកាលយើងលើកទំនប់ហូបបាយ?

គីង : ចាស កាលលើកទំនប់ហូបបាយដល់យើងនៅតាមភូមិគេឲ្យហូបបបរ ។

ឈុនលី : បបរប៉ុន្មានវែកមីង?

គីង : ហ៊ឺស!បបរម៉ាវែកហ្នឹងណាសបើយើងពីបបរសុទ្ធតែម៉ាវែកទេផុតពីនោះទឹកទាំងអស់ តែយើងចេះរកបន្លែក្រៅដែលយើងដាំណាសស្លហូបទៅ តែត្រីសាច់អីមិនដឹងនៅអីណាទេ ។ វេទនាណាស់ ខ្ញុំនិយាយឲ្យកូនស្តាប់ កូនខ្ញុំវាចង់សើចហើយទីបញ្ចប់ពេលដែលយើងហូបអត់ឆ្អែតយើងទៅជីកអាគ្តិលចេកយកមកហូប អាចេកណាដែលឡើងគល់ជីកទៅយកមកស្ងោរហូបអានោះឯងក្មួយអើយ ។

ឈុនលី : ចុះគេអត់ថាអីទេទៅជីកចឹង?

គីង : អាចេកដែលជីកខ្លួនឯងគេអត់ថាអីទេកុំឲ្យតែទៅរកអារបស់រួម ។

ឈុនលី : តែកន្លែងខ្លះគេអត់ឲ្យជីកទេណាស?

គីង : ពួកខ្ញុំដឹកបាន ហើយដំឡូងយើងដាំខ្លួនយើងបានហូប ដំឡូង សាគូអីណាស ហើយដំឡូងនោះដូចថាយើងដាំចំការតូចៗនិយាយពីវាចុះនោះដូចថាយើងចិញ្ចឹមក៏បានដែរ សាគូក៏ដោយក្នុងម៉ាគុម្ពចុះឡើងស ។

ឈុនលី : សំបូរមើមហ្អី?

គីង : ចា៎!ធំៗជាងមេជើង តែអារឿងវេទនា វេទនាត្រង់ថា យើងហូបអត់ឆ្អែតយើង រកអានោះបានហូបដូចជាកន្ទក់ គេចែកកន្ទក់ឲ្យយើងយកទៅធ្វើអន្សម ដាំបាយត្រកួន ដាំបាយដើមចេក បាយល្ពង...

ឈុនលី : លាយហ្អី?

គីង : លាយណាស អង្ករមួយគ្រាប់ៗទៅយើងដាំជាមួយទៅហើយត្រកួនយើងហាន់ឲ្យល្អិតៗ ។ ហើមណាស ពុកខ្ញុំក៏ហើយ គ្រួសារខ្ញុំក៏ហើយ ប្អូនខ្ញុំដែលនៅកៀនវត្តមានម៉ាស៊ីនស្រូវនិយាយពីហើមខ្ញុំថាងាប់ហើយ ឪខ្ញុំពោះក៏ហើយ ប្តីក៏ហើមដៃអីហើមអស់ ។ បានខ្ញុំថាវេទនាណាស់ ខ្ញុំនិយាយប្រាប់កូនខ្ញុំថា កូនអើយ!ម៉ែស្លៀកតែសំពត់ខ្មៅ អាវខ្មៅ វាថាវាមិនជឿ ចុះវាដែលជឿហ្អស សើចទាំងបីនាក់ ។

ឈុនលី : ម៉េចបានទៅជានាំគ្នាសើចវិញ?

គីង : វាថាវាអត់ជឿនោះ ព្រោះសម័យនេះវាតាំងពីកុយទាវ មី បាយស្អី!វាដែលជឿថាយើងហូបកន្ទក់ហ្អស វាមិនជឿវានាំគ្នាសើច ។

ឈុនលី : ចុះឥឡូវនៅតែអត់ជឿទៀត ។

គីង : សព្វថ្ងៃវាជឿខ្លះហើយ ។

ឈុនលី : ចុះដល់ពេលអត់ជឿចឹងមីងខឹងដែរ?

គីង : ទេ ខ្ញុំខឹងហើយបើខ្ញុំខំតស៊ូតាំងពីណាពីណើមកដល់វានាំគ្នាសើចខ្ញុំថា ឆ្កួត!សើចអី ដឹងថាម៉ែឪវេទនាចង់ងាប់ៗ ដូចវាសួរថាមែនឬអីម៉ែ ខ្ញុំថាកូនអើយ!ប៉ុណ្ណោះហើយម៉ែដែលទៅនិយាយកុហកហ្អី ហើយយើងមិនដែលបានទៅអង្គុយលេងទេណា តែមានគ្នាប្អូនប្រាំនាក់ទៅនិយាយលេងអត់បានទេ ហើយឈឺណាស ទោះបីយើងទៅនិយាយប្រាប់វា វាថាឈឺសតិអារម្មណ៍នោះឯង ចឹងបានថាយ៉ាប់ ។

ឈុនលី : ចុះដូចអ្នកដែលមកពីភ្នំពេញដែលអត់ធ្លាប់ធ្វើការអីចឹងមិនមានបញ្ហា?

គីង : ទេ ដូចនៅភូមិខ្ញុំទៅចេះតែទៅធ្វើទៅណាស ដូចថាយើងទៅធ្វើការចឹងគេឲ្យហូបឆ្អែតដូចដំឡូងមី ដូចជាពោតចឹងគេមិនឲ្យយើងអត់ទេ ហើយនៅតាមមុខព្រួញចឹងគេឲ្យយើងដាំបាយឬក៏បបរទន់ៗ បើយើងនៅភូមិមិនបានធ្វើអីគេឲ្យបបររាវ ។

ឈុនលី : ហើយមានអ្នកស្លាប់ទេ?

គីង : បើរឿងអ្នកស្លាប់មិនចេះខ្វះទេ ។

ឈុនលី : ឈឺស្លាប់?

គីង : ឈឺស្លាប់ណាស នេះដាក់នៅទីងវត្តនេះឯង ។

ឈុនលី : វត្តហ្នឹងគេយកទៅធ្វើពេទ្យ?

គីង : ចាស!

ឈុនលី : ចុះលោកនៅក្នុងនោះអី?

គីង : មានលោកឯណាបើវាដេញឲ្យសឹកអស់ហើយ ។

ឈុនលី : សឹកលោកនៅក្នុងនោះអស់ហើយ?

គីង : សឹកអស់ហើយ ។

ឈុនលី : ហើយឲ្យទៅធ្វើការដល់ណាទៅ?

គីង : អូស!លោកទៅតាមស្រុកតាមស្រែអស់ហើយ ។

ឈុនលី : មីងដឹងទេរឿងគេដេញលោកចេញ?

គីង : ទេ ខ្ញុំមិនដឹងទេ ។

ឈុនលី : ព្រោះគេថាហ្អី?

គីង : ទេ ព្រោះគេថាអី ប្ដីខ្ញុំនេះឯងកាល៧៥គាត់មិនទាន់សឹកផងហ្នឹង ។

ឈុនលី : ចឹងគាត់ធ្វើលោកដែរ?

គីង : ចាស!ធ្វើលោក គាត់គ្រូសូត្រស្ដាំពីដើមមិញ ហ្អស!នៅវត្តនេះឯងដល់គេជម្លៀសទៅស្រែះ គេជម្លៀសលោកទៅដែរ ផ្សឹក ទេដូចមិនទាន់ផ្សឹកទេ ហ្អស!ទៅផ្សឹកអីស្រែះនោះឯង ផ្សឹកលោកទាំងអស់ ។

ឈុនលី : ផ្សឹកហើយឲ្យធ្វើការ?

គីង : ឲ្យធ្វើការ រួចដូចថាអ្នកណាគ្រួសារនៅឯណាឲ្យទៅឯនោះណាស ដូចគ្រួសារខ្ញុំនេះ ម្ដាយគាត់នៅជើងវត្ត គាត់នៅជើងវត្ត ។

ឈុនលី : ហើយរួចហើយវត្តហ្នឹងយកទៅធ្វើពេទ្យ?

គីង : ចាស!ដាក់ធ្វើពេទ្យ ហើយងាប់ច្រើនណាស់ ក្មេងក៏ងាប់ចាស់ក៏ងាប់ ។

ឈុនលី : ងាប់ដោយសារអីភាគច្រើន?

គីង : អាជំងឺរាគរូសនោះឯង គ្រាន់តែជំងឺរាគ គ្រុន គ្រុនចាញ់ ។

ឈុនលី : ហើយដល់ពេលស្លាប់ យកទៅកប់នៅឯណាទៅ?

គីង : កប់ក្នុងព្រៃ ។

ឈុនលី : ភាគច្រើនអ្នកចាស់ឬអ្នកថ្មីដែលស្លាប់?

គីង : ស្លាប់ដូចគ្នាអ្នកចាស់ក៏ងាប់ អ្នកថ្មីក៏ងាប់ ។

ឈុនលី : មិនមែនថាអ្នកថ្មីអត់ធ្លាប់ធ្វើអីទេ?

គីង : អត់ទេ អ្នកថ្មីក៏ងាប់ អ្នកចាស់ក៏ងាប់ ។ អ្នកចាស់ងាប់ដែរ ងាប់ច្រើនចាស់ៗ ។

ឈុនលី : ដល់ពេលអ្នកថ្មីស្លាប់ក្មេងហ្អី?

គីង : ចាស!

ឈុនលី : ចុះយកវត្តធ្វើពេទ្យចឹងដូចព្រះដូចអីចឹងយកទៅណា?

គីង : ចុះបើវាវៃចោលខ្ទេះ វាវៃបំបាក់ក ព្រះធំៗវាវៃបំបាក់កទើបតែជិតទាវទិញខ្លួនមកបានៗត ព្រះកេស ។ តទើបតែឆ្នាំទៅមួយ ។

ឈុនលី : អីចឹង?

គីង : ចាំ!

ឈុនលី : ចុះព្រះហ្នឹងវៃនៅសល់តែត្រឹមកទេ?

គីង : សល់តែខ្លួនទេ ហើយព្រះកេសនោះមិនដឹងដាវាទំលាក់ទឹកឯណាទេ ទើបតែរកឃើញទេដឹង នេះគេធ្វើឆ្នាំទៅមួយនេះឯង តែព្រះកេសនេះបែបធ្វើថ្មីនៅតែខ្លួន ។

ឈុនលី : ចុះមីងដែលឃើញទេ?

គីង : ដែលគេធ្វើរួចហើយទេបានឃើញ ។

ឈុនលី : បើអាកាលចូលពេទ្យហ្នឹងអត់ឃើញទេ?

គីង : អត់ឃើញទេ អត់ទេបើខ្ញុំមិនដែលបានទៅផង ។

ឈុនលី : ចុះពេលឈឺនោះ?

គីង : ពេលឈឺខ្ញុំអត់ទៅពេទ្យហ្នឹងផងទៅតែពេទ្យស្រុក ។

ឈុនលី : ចុះពេទ្យនេះហើយពេទ្យស្រុកខុសគ្នាយ៉ាងម៉េច?

គីង : ទេ ទៅធ្វើការតាមទំនប់គេឲ្យយើងដេកពេទ្យស្រុកណាស ពេទ្យនេះនៅតាមឃុំ...

ឈុនលី ៈ ចុះដូចមីងទំងន់ត្រូវសំរាលកូនអីសំរាលនៅឯណា?

គីង ៈ សំរាលនៅផ្ទះ ឆ្មបខ្មែរអត់បានទៅពេទ្យទេ ឆ្មបអ្នកស្រុកយើង ។

ឈុនលី ៈ ហើយសំរាលនៅផ្ទះចឹង សំរាលបានប៉ុន្មានថ្ងៃបានទៅធ្វើការ?

គីង ៈ កូនដូចធំដែរ ព្រោះខ្ញុំសំរាលបានប្រហែលប៉ុន្មានខែអីចេះ ប្រាំបីខែសន្តិភាព ។ ខ្ញុំក្រមាន កូន ដូចជាខ្ញុំទំនេរពោះបានម៉ាឆ្នាំ មិនបានប៉ុន្មានទេស្រុកសន្តិភាព ។

ឈុនលី ៈ ហើយដល់គ្រួសារមីងគាត់ទៅធ្វើការអីគេបន្ទាប់ពីសឹកហើយ?

គីង ៈ ដល់សឹកហើយនោះគេឲ្យយើងធ្វើការតាមភូមិ គាត់ដាំដំឡូងដាំអី គាត់ធ្វើការតាមភូមិហើយ បានទៅលើកទំនប់ ។ លើកទំនប់ជុំគ្នារហូតមក ។

ឈុនលី ៈ ហើយចុះមីងមកភូមិដោយសារពោះធំ មកភូមិចឹងគាត់នៅឯណា?

គីង ៈ គាត់មកដែរ ។

ឈុនលី ៈ សុំគេបានទៀត?

គីង ៈ ចា៎! សុំគេបានមក ។

ឈុនលី ៈ ស្រួលហើយចឹង?

គីង ៈ មកហើយគាត់គេឲ្យកាន់រទេះគោដឹកសំណាបដឹកអីឲ្យគេ ។

ឈុនលី ៈ ហើយយើងដេរនៅផ្ទះ?

គីង ៈ ចាស! ខ្ញុំដេរនៅសហករណ៍នោះទៅមិនបាននៅផ្ទះដងហ្នឹង ។

ឈុនលី ៈ ហើយចុះសំរាកអីនៅទីនោះដែរ?

គីង ៈ ទេ ដល់ល្ងាចបានយើងមកផ្ទះ ។

ឈុនលី ៈ ចឹងមើលទៅដូចគេចែករបបឲ្យនៅតាមផ្ទះ?

គីង ៈ ទេ តាមសហករណ៍ណាសនាង ។

ឈុនលី ៈ យើងហូបអីហើយបានមកផ្ទះ?

គីង ៈ ទេ យើងមកហូបនៅកន្លែងរួមដូចម៉ារយគ្រួសារអីចឹងគេដាក់ធ្វើម៉ារោងមួយ យើងមកហូប នៅកន្លែងរួមជាមួយគេ ហើយយើងដើរមកធ្វើការ ។

ឈុនលី ៈ ហើយយប់ឡើងចឹងមានគេយាមទេ?

គីង ៈ ទេ មានឈ្លបគេយាមដែរហ្នឹង ។

ឈុនលី ៈ ហើយមានដែលឮអ្នកណាបេះអី លួចអីហូបទេ?

គីង : អត់ ខ្ញុំមិនដែលប៉ះទេ ព្រោះនៅម្ដុំខ្ញុំសុទ្ធតែអ្នកដាំ ព្រោះយើងលើកផ្ទះចឹងនៅសល់ដីតិចៗខាងក្រោយចេះតែដាំទៅណាស បន្លែស្អីក៏យើងដាំដែរបានៗហូបដូចជាដំឡូងមី សាគដំឡូងដូងអីយើងចេះតែដាំទៅ ព្រោះអីយើងបេះបន្លែផ្សំ តែបើត្រីមិនដឹងនៅឯណាទេទាល់តែស្ងោរចេះតែប៉ុណ្ណោះឯងហូប ។

ឈុនលី : ចឹងមីងអត់ដែលឃើញគេចាប់មនុស្សទៅណាៗទេ?

គីង : អត់ទេ អត់ដែលទេ ។

ឈុនលី : អត់ដែលឮទៀត?

គីង : អត់ ទេ!អារឿងឮៗហើយ តែយើងមិនដែលឃើលផ្ទាល់ភ្នែកយើងគ្រាន់តែឮគេនិយាយដឹងថាគេនិយាយថាចាប់អ្នកនេះចាប់អ្នកនោះ ។

ឈុនលី : ចុះមានឮគេនិយាយទៀតទេថាស្លាប់ដោយសារអី?

គីង : ខ្ញុំមិនដឹងទេ ។

ឈុនលី : ចុះមីងភ័យទេ?

គីង : ភ័យ តែដូចក្នុងគ្រួសារខ្ញុំមិនមានទាហានមិនមានគ្រូមិនមានទាហានចឹងវាធម្មតាណាសព្រោះអ្នកដែលគេចាប់ហ្នឹងចាប់តែអ្នកទាហានអ្នកមានប្រវត្តិរូបអី តែម៉ែឪខ្ញុំអ្នកស្រែខ្ញុំភ័យដែរតែយើងចេះតែគេចទៅណាស ។

ឈុនលី : ឪពុកមីងពីដើមគាត់ធ្វើអីគេ?

គីង : ធ្វើស្រែ ធ្វើស្រែរហូតមក តែខ្លាចដែរណាមួយខ្លាចវាខុសឈ្មោះនោះណាស ដូចថាគេទេតែយើងចេះតែភ័យទៅណាស ។

ឈុនលី : ព្រោះអីគេចាប់ទៅគេមានសួរនាំអី!

គីង : ចាស!គេអត់សួរទេ គេដឹងតែចាប់ឈ្មោះនោះទៅចាប់ទៅ ។

ឈុនលី : ចុះដែលឮនៅភូមិផ្សេងទៀតមានរឿងគេសំលាប់ទេ?

គីង : ខ្ញុំនេះដូចថាហឺៗមិនចង់ដឹងរឿងអី ព្រោះអីវាវេទនាខ្លួនឯង ហើយថាទៅគេមិនឲ្យយើងនិយាយរឿងដុំៗអីអត់ យើងមិនដឹងរឿងណាស ឲ្យយើងនៅផ្សេងៗគ្នា ។

ឈុនលី : ចុះអាកាលរឿងខុសសីលធម៌ដែលគេចាប់យកទៅចងនៅមុខវត្តនោះ?

គីង : នោះមិនដឹងនៅភូមិណា នៅភូមិស្រែះទេដឹងវៃទីនេះឯង ។

ឈុនលី : មីងដឹងរឿងនោះដែរ?

គីង : ទេ ខ្ញុំដឹងថាខុសសីលធម៌ វៃអីក៏ឃើញដែរ ។

ឈុនលី ៖ ម៉េចខ្លះទៅមីងពីដំបូងមកយ៉ាងម៉េច?

គីង ៖ ពីដំបូងគេធ្វើការប្រាប់ថាមនុស្សប្រុសស្រីនេះខុសសីលធម៌ឡើងមានកូន ហើយគេដឹកសីលធម៌សសរឡើងធំចងទល់ខ្នងគ្នាណាស នោះខ្ញុំឃើញហើយដាក់ស្តែង ហើយគេវ៉ៃប្រុសហើយបានគេវ៉ៃស្រី តែស្រីមិនងាយងាប់ទេព្រោះពោះធំ ។

ឈុនលី ៖ ចុះគេយកអីវ៉ៃ?

គីង ៖ ដងជីទឹកឡើងវែង ដងចប ។ ដូចថាគេវ៉ៃទៅស្រាប់តែគេប្រកាសប្រាប់យើងថា យើងមិនត្រូវមានការតក់ស្លុតមិនហ៊ានមើលហ៊ានអីណាស តែអ្នកខ្លះ ខ្ញុំចេះតែលួចមើលថាដំណើរវាយ៉ាងម៉េចខ្លះចឹងណាស ។

ឈុនលី ៖ ហើយមនុស្សមកច្រើនទេ?

គីង ៖ ហូស!វាហៅមកច្រើនតាំងពីស្រមោច ស្រេះ ដូនប្រែងមកទាំងអស់ម៉ាឃុំហ្នឹងវាហៅមកទាំងអស់ ។ អានៅកាច់ជ្រុងនេះ ។

ឈុនលី ៖ ចាស!នៅជិតវត្តព្រះនេត្រព្រះ ។

គីង ៖ ហ្នឹងហើយ ឈានវត្តបន្ទិច ។

ឈុនលី ៖ កន្លែងដើមច័ន្ទការី?

គីង ៖ ចាស!កន្លែងដើមច័ន្ទការីធំៗខាងជើង ។

ឈុនលី ៖ ហើយទៅយ៉ាងម៉េចមីង?

គីង ៖ ដល់ពេលគេប្រកាសរួចទៅ មុនដំបូងអត់មានអ្នកណាតក់ស្លុតទេ ដល់វាប្រកាសថានេះអ្នកខុសសីលធម៌ដែលស្រលាញ់ប្តីគេ ប្រពន្ធគេក្រមុំកំលោះអីក៏ដោយត្រូវតែគេយកមកវ៉ៃចោលកុំឲ្យអ្នកផ្សេងយកគំរូតាម ។

ឈុនលី ៖ ហើយពោះធំទៀត?

គីង ៖ ពោះធំ ។

ឈុនលី ៖ ឈ្មោះអីទៅមីង?

គីង ៖ អត់ស្គាល់ទេខ្ញុំនៅឆ្ងាយដូចថាគេចង...

ឈុនលី ៖ មីងដឹងថាពីរនាក់ដែលស្រលាញ់គ្នាហ្នឹងមកពីស្រុកណាទេ?

គីង ៖ ដឹងថានៅស្រេះ...

ឈុនលី ៖ នៅស្រេះ?

គីង : ចាំ!នៅភូមិស្រែះ ទេមិនដឹងជាស្រែះ ស្រមោច ហ្អីដួនប្រែងទេព្រោះយកមកពីក្រោមនោះឯង ។

ឈុនលី : ហើយវើម៉េចទៅមីង?

គីង : វាវើហ្នឹងចប ថាវើឡើងរាប់ទៅវាសំយ៉ុង ។

ឈុនលី : វើកន្លែងណាទៅ?

គីង : វើកន្លែងនេះ ។

ឈុនលី : ប្រុសហ្នឹង?

គីង : ស្រីក៏វាវើអីចឹងដែរដូចតែគ្នា ។

ឈុនលី : ចុះមីងថាស្រីហ្នឹងវើទៅក្រស្វាប់?

គីង : វើអីចេះ វើពីក្រោយ ។

ឈុនលី : ម៉េចបានអីចឹង?

គីង : ចុះបើមានកូននៅក្នុងពោះ ។

ឈុនលី : ម៉េចបានចឹង?

គីង : ទេ មិនដឹងដែរ ។

ឈុនលី : ចុះធម្មតា ស្រីកំលាំងខ្សោយជាង?

គីង : ខ្សោយមែន តែយើងមានកូន ដូចថាកូនវាអត់ទាន់ដាច់ខ្យល់ ។

ឈុនលី : ចឹងមិនស្រែកពេញហ្នឹងហើយ?

គីង : ហ៊ឺស!ស្រែកមិនរួចទេក្អួយអឺយ ដូចថាសសរណាស គេចងចេះប្រុសក៏គេចងចេះហើយសសរនៅកណ្តាលណាស ។

ឈុនលី : ម្នាក់ៗហ៊ានយំដែរ?

គីង : អត់ហ៊ានយំទេ គ្រាន់ដៃដាក់មុខចុះគេមិនឲ្យដាក់ផង ។

ឈុនលី : គេឲ្យយើងមើល?

គីង : គេឲ្យយើងមើលកុំឲ្យយកគំរូរតាម ។

ឈុនលី : ចុះពីរនាក់គាត់មានពុកម្តាយមកមើលដែរអត់?

គីង : អត់ទេ ដូចជាអត់មានអ្នកណាមកមើលទេដូចជាតែពីរនាក់ប៉ុណ្ណោះឯងបើម៉ែឪក៏មិនហ៊ានមកតាមដែរ ។

ឈុនលី : ហើយប្រហែលប៉ុន្មាននាទីទៅបានស្លាប់?

គីង : ទេ កន្ទះម៉ោងជាងទៅណាស ។

ឈុនលី : ហើយគេស្រាយយកទៅ?

គីង : គេស្រាយយកទៅក៏មិនដឹងយកទៅណា ដូចថាគ្រាន់តែវ៉ៃហើយគេឲ្យយើងចេញអត់មានអ្នកណាហ៊ានមាត់ទេ ដូចថាយើងលាន់មាត់តែគ្នាយើងបានតែយើងអត់ឲ្យគេឮទេ ។

ឈុនលី : ហើយពេលមីងត្រឡប់មកផ្ទះវិញខ្លាចអត់?

គីង : វាស្រមៃនៅតែនឹងភ្នែក ។

ឈុនលី : មានយល់សប្តិដែរទេ?

គីង : អត់ទេ តែគ្រាន់ថាស្រមៃព្រោះគេវ៉ៃហ្នឹងវាជាក់ស្តែងពេក បានជាមិនមានអ្នកណាហ៊ានស្រលាញ់គ្នាប្រុសក៏ដោយស្រីក៏ដោយប្រពន្ធគេប្តីគេក៏ដោយអត់មានអ្នកណាហ៊ានស្រលាញ់ទេតាំងពីវ៉ៃអាប៉ុនោះមកហើយមីនាងនោះស្លាត់ជ្រាប ។ ហ្អស!មានដែរដូចថាពួកគេមេបញ្ជាការធំៗគេស្រលាញ់គ្នា គេជម្រត់គ្នាទៅតាមតំបន់ផ្សេងៗគ្នាណាស!

ឈុនលី : មេៗទៀត?

គីង : មេ ពួកនិរតី ពួកបច្ចឹម ពាយ័ព្យឯណា ។

ឈុនលី : កាលមីងមកនៅភូមិនេះ ពួកនិរតីមកនៅហើយឬនៅ?

គីង : មកហើយ និរតី បច្ចឹម ។

ឈុនលី : អ្នកណាគេខាងនិរតីមីងស្គាល់ឈ្មោះទេ?

គីង : អត់ ។

ឈុនលី : ចុះមីងស្គាល់ឈ្មោះ យាយថែម ទេ?

គីង : យាយថែម ស្គាល់តែឈ្មោះតែមិនដឹងរូបយ៉ាងណា ឬតែគេថានៅខាងរំដួក ភ្នំលាប ។

ឈុនលី : ភ្នំលាប?

គីង : ចាស!

ឈុនលី : អាហ្នឹងភូមិហ្អី?

គីង : ភ្នំលាប ឃុំភ្នំលាបនេះឯង ។

ឈុនលី : នៅឆ្ងាយទេ?

គីង : ឆ្ងាយ អាយើងពីនេះទៅតាមថ្នល់ទៅខាងរំដួលទៅបានទៅដល់ភ្នំលាប ។

ឈុនលី : ចឹងគាត់កាន់របៀបនៅខាងនោះទេ?

គីង : ចាស គាត់កាន់អ្នកខាងនោះ គាត់ធ្វើបាបអ្នកខាងនោះតាមនិយាយ ។

ឈុនលី  :  ចឹងគាត់កាចហ្អី?

គីង  :  ទេ មិនដឹងដែរព្រោះតែឈ្មោះ យាយថែមៗ ។

ឈុនលី  :  ហើយគេថាគាត់ធ្វើបាបហ្អី?

គីង  :  នោះផែព្រោះតែគេថាគាត់វ៉ៃគេអីណាស ។

ឈុនលី  :  ចុះអ្នកនៅនេះឈ្មោះតាវ៉ាល់ហ្អី?

គីង  :  តាវ៉ាល់ ហ្នឹងគាត់កាន់តែទំនប់ទេ គាត់មិនកាន់តាមភូមិទេ កាន់តែតាមពួកចល័តណាស ។

ឈុនលី  :  ហើយចុះមកនៅក្នុងភូមិអ្នកណាអ្នកកាន់?

គីង  :  មិនដឹងឈ្មោះអីទេ ពួកពាយ័ព្យ ពួកបច្ចឹម និរតីខ្ញុំអត់ស្គាល់ឈ្មោះទេ ។

ឈុនលី  :  តែគ្រាន់តែថាពេលនោះពួកពាយ័ព្យហ្នឹងអាចថាគេយកទៅម៉ាសាហើយបានគេយកពួកនិរតីទៅទៀតហ្អី?

គីង  :  ត្រូវហើយ ។

ឈុនលី  :  តែអាហ្នឹងពេលមីងមកនៅភូមិហើយតើហ្អី?

គីង  :  មកហើយ តែខ្ញុំអត់ស្គាល់ព្រោះយើងមិនដែលបាន ។

ឈុនលី  :  ចុះដូចមានមេមកថ្មីចឹងគេអត់មានប្រកាសប្រាប់ទេ?

គីង  :  គេប្រាប់ ដូចថាខ្ញុំពោះធំចឹងមិនដែលបានទៅប្រជុំអីនឹងគេនោះណាស មានតែអ្នកនៅកាន់នេះមិនដឹងអ្នកណាប្រធានអ្នកណាអីទេ តែឈ្មោះចេះតែស្គាល់ហើយ ឈ្មោះអីទេ ភ្លេចបាត់ហើយនាងអើយ ឈ្មោះង៉ែត នៅភូមិខ្ញុំឈ្មោះង៉ែតស្រីណាស ពួកនិរតី ។

ឈុនលី  :  គាត់ធ្វើអីចេះ?

គីង  :  គាត់ក្ដាប់រួមម៉ាភូមិនេះឯង កាលនោះឡើងបួនប្រាំនាក់ខ្ញុំស្គាល់តែមួយ ។

ឈុនលី  :  គាត់កាចទេ?

គីង  :  មិនដែលបានប៉ះគាត់ចឹង កាលទៅធ្វើការក៏មិនដែលបានប៉ះគាត់ចឹងប៉ះតែអ្នកផ្សេងៗ ។ ខ្ញុំនោះវេទនាតែទៅលើកទំនប់លើកអីនោះ យើងកំលាំងខ្សោយទៅលើកវាមិនទាន់គេចឹងឯង ។ ហើយមកភូមិហុតតែទឹកបបរ អត់មានជាតិបបរទេ ទឹកទទេ អត់មានគ្រាប់អង្ករមានអីទេ ។

ឈុនលី  :  ចុះមីងថាដាំបាយលាតល្ហុងលាយអីហ្នឹងដាំពេលណា?

គីង  :  ដាំពេលដែលថាគេចែកមកមិនគ្រប់ចេះតែលួចដាំ ។

ឈុនលី  :  លួចដាំតើហ្អី?

គីង : លួច មិនមែនទៅដាំចំហរនឹងមុខគេទេ តែនឹកឃើញថាយើងដាំបាយលាយចឹងមិនខ្វាចដូចអាយើងដាំបាយសុទ្ធ ។ ដូចថាយើងដាំបាយសុទ្ធខ្វាចគេយកទៅវ៉ៃចោល ។

ឈុនលី : អត់ដែលមានគេឃើញទេ?

គីង : ទេ យើងសុទ្ធតែលួចដាំ ។ លួចដាំហើយមិនហ៊ានដាំនឹងឆ្នាំងផង ដាំតែនឹងកំសៀវ ។

ឈុនលី : លួចហ្នឹងលួចអង្ករយកមកម៉េង?

គីង : ហ្នឹងហើយដូចថាយើងទៅសុំគេណាស ទៅសុំប្រធានខាងអង្ករ យើងសុំគេទៅយកមកបានម្នាក់ម៉ាកំប៉ុងទៅយើងលាយទៅណាស ។ គេមិនឲ្យទៅយើងដាំដាក់តែអំបិលទៅ ម្សៅស៊ុបក៏អត់មានដែរ ។

ឈុនលី : មានតែអំបិល?

គីង : មានតែអំបិល តែប្រហុកក៏មិនមានផង មិនមានប្រហុកនឹងក្រឡុទេ ។

ឈុនលី : ហើយមីងប្រាប់កូនចឹង ខស្សារប្រាប់ហ្អី?

គីង : ប្រាប់ពីតូចធំ រាល់ថ្ងៃក៏ដោយនិយាយប្រាប់ តែកាលនោះនិយាយប្រាប់ទាំងអស់គ្នាក្មេងៗដែលនៅរៀនថា អឺឯនិយាយតិចមើលខ្ញុំដូចចង់ស្តាប់ ។ បានខ្ញុំនិយាយដំណើររឿងរ៉ាវវាថាវេទនាមែនអ៊ឺ ។

ឈុនលី : ចុះមីងមាននិយាយអារឿងវ៉ៃមនុស្សទេ?

គីង : ប្រាប់ណាស ប្រាប់វាឲ្យដឹង ។

ឈុនលី : ហើយម្នាក់ៗថាម៉េចទៅ?

គីង : ថា សម័យនោះ បើសម័យសព្វថ្ងៃអ្នកណាស្រលាញ់អ្នកណាក៏ស្រលាញ់ទៅ បើសម័យនោះគេវ៉ៃចោល ។

ឈុនលី : ចុះមីងមកដល់ឥឡូវដូចថាស្លៀកខោអាវខ្មៅជំនាន់នោះណាស រហូតមកដល់ឥឡូវមីងស្លៀកពាក់ខោអាវខ្មៅទៀតទេ?

គីង : ទេ ទិញប៉ះខ្មៅដែរ ។

ឈុនលី : ចុះទិញប៉ះខ្មៅចឹងនឹកឃើញទេ?

គីង : នឹកឃើញ ឲ្យតែលើកអាវពាក់ចេះតែនឹកឃើញថា ហ៊ឹស!អញកាលសម័យនោះស្លៀកសំពត់ខ្មៅអាវខ្មៅបង់ករកន្សែង ។

ឈុនលី : តែអត់មានចិត្តថាស្អប់អីទេ?

គីង : ទេ វាមានដូចចេះហើយទុកដូចថាធម្មតាណាសនាង!

ឈុនលី ៖ ចឹងឥឡូវលែងមានហើយ?

គីង ៖ វាយូរទៅហើយដូចថាវាលែងគិតទៅហើយ ប៉ុន្តែតាមតែនឹកឃើញម៉ាឆាវៗ ។ ដល់វាយូរទៅរបៀបថាដូចភ្លេច ។

ឈុនលី ៖ ដោយសារឥឡូវសប្បាយអីចឹងណាស ស្រុកឥឡូវវាធូរ ។ ។

គីង ៖ ខ្ញុំចេះតែនឹកឃើញអត់ភ្លេចទេ ។

ឈុនលី ៖ បើម៉ែខ្ញុំគាត់ស្អប់តែម្តងមីង រឿងខោអាវខ្មៅហ្នឹងគាត់អស់ស្មៀកទៅជាពិសេសអាវណាស បើខោកាត់អត់ថាអីទេ ហើយបើអាវកាត់អត់ពាក់ទេ កាលខ្ញុំនៅតូចៗក៏អត់ឲ្យពាក់ដែរ ។

គីង ៖ ខ្ញុំ កូនអត់មានទេពណ៌ខ្មៅ ។

ឈុនលី ៖ អត់ឲ្យស្លៀកហ្អី?

គីង ៖ ឲ្យស្លៀក មិនទិញឲ្យគេម្តងទិលតែពណ៌ផ្សេងៗ ។

ឈុនលី ៖ ចុះហេតុអីបានទិញខ្លួនឯង?

គីង ៖ ដូចអីចេះ ដូចខ្ញុំដែលទិញខ្ញុំទិញតែជជុះទេ បើឲ្យកាត់អីអត់កាត់ទេខ្មៅ ។ ដូចអារបស់ជជុះថោកៗមួយម៉ាពាន់អីបានទិញពាក់ចោលទៅ តែបើឲ្យទិញថ្មីអត់ទិញទេ ។

ឈុនលី ៖ ស្អប់ហ្អី?

គីង ៖ ស្អប់ ។

ឈុនលី ៖ អាក្រមាអីចឹង?

គីង ៖ ចាស!

ឈុនលី ៖ ក្រមាពីដើមមានប្រហែលចឹងទេ?

គីង ៖ ហ្អស!មិនបានប៉ុណ្ណេះទេនាងអើយ ។ ទេ បើត្បាញនៅតាមភូមិក្រាស់ តែបើត្បាញដូចយើងសព្វថ្ងៃស្តើង ។

ឈុនលី ៖ ហើយខោអាវស្តើងៗដែរ? ខោអាវស្លៀកបានប៉ុន្មានទៅមីងស្តើងៗចឹង?

គីង ៖ មិនបានប៉ុន្មានទេ តែសម័យនោះយើងមានអាខោអាវយើងល្អៗយកទៅជ្រលក់គេមិនឲ្យយើងពាក់ពណ៌នោះ ហើយយើងចេះតែជ្រលក់ទៅពណ៌ស្អីក៏ជ្រលក់ដែរ ។ ពណ៌គំរមានណាស់មួយៗ ផ្កាអីមួយៗ បើយកទៅជ្រលក់ខ្មៅអស់ សំពត់ក៏ខ្មៅ សាច់ក្រណាត់គេបើកឲ្យ ។

ឈុនលី ៖ ចុះដូចកូនស៊ាំអីកន្ទុបពិបាករក?

គីង : ហ៊ឺស!មានអីក្មួយអើយចេះតែហែកកណ្តាចចេះតែទ្រាប់គ្នាទៅ វេទនាសំពត់សឹងតែដាច់ទៅ ដាច់មកមិនដែលមានអីឲ្យបានពីរបីឲ្យយើងដាស់ទេ ។

ឈុនលី : ចុះមីងឥឡូវដែលពូរៀងតុលាការកាត់ទោសខ្មែរក្រហមទេ?

គីង : ខ្ញុំមិនដែលបានស្តាប់ទេ ទូរទស្សន៍ក៏មិនដែលបានមើលដែរ ។

ឈុនលី : វ៉ាត់យូ៉អត់មានដែរ?

គីង : វ៉ាត់យូ៉មានដែរតែពិបាកអាខ្ញុំមិនដែលបានស្តាប់ ។

ឈុនលី : ចុះអត់ដែលពូគេនិយាយទេ?

គីង : ទេ ពូគេនិយាយហើយ កាលពួកបងហ៊ុយអីទៅ ពួកខ្ញុំអាលើកក្រោយនេះថាទៅដែរ ដល់នេះទៅថាឈប់យក ។

ឈុនលី : តែដល់ពេលពួកគាត់ទៅចឹងមកវិញគាត់ប្រាប់ទេ?

គីង : ទេ មិនដែលបានជួបគាត់ផងនោះ ។

ឈុនលី : តែអ្នកផ្សេងទៀត?

គីង : អ្នកផ្សេងគេនិយាយ និយាយពីរឿងកាត់ទោសខ្មែរក្រហមអី តែខ្ញុំមិនចាប់អារម្មណ៍ទេខ្ញុំនេះណាស តែនិយាយទៅប្រៀបថាវ៉ាមិនមានអីឲ្យយើងហូប ប្រៀបតែប៉ុណ្ណោះឯង ។ បើយើងអត់ទៅធ្វើការឈឺ ដៀលយើងសុទ្ធតែសតិអារម្មណ៍ស្អី១ ។

ឈុនលី : ចុះដល់ពេលមីងពូថាកាត់ទោសចឹងមីងមានអារម្មណ៍ថាម៉េចទៅ?

គីង : ចុះបើយើងមិនដែលស្តាប់គេថាម៉េចផង បើវ៉ាត់យូ៉ក៏ខ្ញុំមិនដែលបានស្តាប់ បើខ្ញុំបើក១តែពេលល្ងាចពេលលោកសូត្រធម៌សូត្រអីប៉ុណ្ណោះមិនដែលបានស្តាប់ពត៌មានអីអត់ ព្រោះខ្ញុំដូចថាមិនមានអារម្មណ៍អីទេតាំងពីប្តីស្លាប់ទៅដូចជាធីងធោងក្នុងខ្លួន ខ្ញុំគិតស្រណោះកូនស្រណោះអីផងទៅក៏ខ្ញុំមិននៅនឹកនាអីទេ ហើយយើងនៅជំពាក់ប្រាក់គេរាប់ពាន់ចេះតែគិតណាស ចឹងបានរឿងអីផ្សេងទៀតខ្ញុំអត់គិត ខ្ញុំគិតតែខ្លួនខ្ញុំដែលខ្ញុំក្រវេទនា ។

ឈុនលី : ចាស ដូចឥឡូវហ្នឹងនៅតុលាការខ្មែរក្រហមមានប្រាំនាក់ដែលគេកាត់ទោសណាមីង មានតាឌុច ដែលមេគុកទួលស្លែង ធ្លាប់ពូទេមីងទួលស្លែង ។

គីង : ពូ ខ្ញុំទៅមើលកាលឆ្នាំ៩០ដែរនោះតែខ្ញុំអត់បានចូលទៅក្នុងទេ ឃើញអាគំនឆ្អឹងនៅនឹងមុខ ។

ឈុនលី : ឆ្នាំ៩០ទៅជាមួយអ្នកណាគេ?

គីង : ខ្ញុំទៅលេងជាមួយប្តីខ្ញុំកាលនោះកូននៅតូច១ ។

ឈុនលី ៖ ចុះម៉េចបានទៅមើលនៅនោះ?

គីង ៖ ដែរផ្ទះប្រជាជនថ្មីហ្នឹងយើងនៅជុំគ្នាណាស នៅជុំគ្នាចេះតែស្គាល់រាប់អាន ដល់ចឹងទៅគេឲ្យយើងទៅលេងណាសដូចថាយើងអ្នកចិត្តលណាស ។

ឈុនលី ៖ អ្នកស្រុកណាអីចេះ?

គីង ៖ នៅភ្នំពេញនោះឯង ផ្ទះជាប់នឹងគុកទួលស្លែងបានទៅឃើញអ្ហឹងឃើញអីហ្នឹង ។

ឈុនលី ៖ ចុះឥឡូវនៅទាក់ទងគ្នាដែរ?

គីង ៖ គាត់ងាប់អស់ហើយ ព្រោះកាលនោះខ្ញុំនៅក្មេង គាត់ចាស់ៗអស់ហើយហ្នឹង ។

ឈុនលី ៖ តាឌុច ហ្នឹងគេកាត់ទោសគាត់ហើយ គេកាត់ទោសតាំងពី២០០៩ ហើយកាលឆ្នាំមុនគេចេញសេចក្តីសំរេចដាក់ទោស៣៥ឆ្នាំ ប៉ុន្តែដល់គេកាត់កុះអីទៅព្រោះគាត់ធ្លាប់បានគេឃុំខ្លួនខុសច្បាប់ចឹងទៅនៅសល់តែ១៩ឆ្នាំទេ ដល់ទៅគាត់ប្តឹងបន្តទៀតប្តឹងទៅថ្នាក់លើទៀត ហើយព្រះរាជអាជ្ញាក៏គេអត់ព្រមដែរ ប្រជាជនអីក៏អត់ព្រមចឹងគេប្តឹងទៅទៀតណាស តែឥឡូវអត់ទាន់ដឹងសេចក្តីសំរេចទេ ហើយចំពោះអ្នកផ្សេងទៀតមាន នួន ជា អៀង សារី អៀង ធិរិទ្ធ ខៀវ សំផន។ បួននាក់ហ្នឹងនៅក្នុងសំណុំរឿងតែមួយ ចឹងនៅចុងខែ៦នេះគេនឹងចាប់ផ្តើមពិភាក្សារឿងគាត់ហើយ ។ ហើយមីងសប្បាយចិត្តទេនៅពេលមានតុលាការចឹង?

គីង ៖ ទេ សប្បាយហើយកាត់ក្តីឲ្យវាចាញ់ទៅព្រោះវាហ្នឹងសំលាប់មនុស្សអស់មិនតិចទេ ។

ឈុនលី ៖ ទោះបីចាស់ទុំអីក៏ដោយហ្អី ព្រោះអីឥឡូវអាយុប៉ែតអីអស់ហើយ?

គីង ៖ ប៉ុណ្ណាក៏ដោយ បើវាមិនបញ្ឈរអ្នកស្រុកម៉េចហ៊ានធ្វើ ។

ឈុនលី ៖ មីងមានអីបន្ថែមទៀតទេមីង?

គីង ៖ ទេ ខ្ញុំអត់មានអីទៀតទេមានតែប៉ុណ្ណោះឯង ។

ឈុនលី ៖ ចឹងអត់មានអីបន្ថែមអីទេ អគុណហើយមីង ។

«ចប់»